លេខ ៨ ខែ សីហា ឆ្នាំ ១៩៩០

# រាជកិច្ច

រួមមាន ៖

- ច្បាប់
- ក្រឹត្យ-ច្បាប់
- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ
- សារាចរណែនាំ

ផ្សាយចេញពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ជារៀងរាល់ខែ

Downloaded from http://www.khmerlaws.com

# មាតិកា

## I — ក្រុមប្រឹក្សារដ្ឋ

### ក្រឹត្យ

១៣ - ៥ - ១៩៩០ ក្រឹត្យលេខ ៩៣ ក្រ ស្ដីពីការតែងតាំងជារដ្ឋមន្ត្រី. ១៩៣
១៧ - ៥ - ១៩៩០ ក្រឹត្យលេខ ៨៨ ក្រ ស្ដីពីការតែងតាំងសមាជិក [illegible] ជាសមាជិក ក្រុមប្រឹក្សារដ្ឋ ១៩៤

## II — ក្រុមប្រឹក្សារដ្ឋមន្ត្រី

### ១ – អនុក្រឹត្យ

០៥ - ៥ - ១៩៩០ អនុក្រឹត្យលេខ ១៥ អនក្រ ស្ដីពីការបង្កើតរបាយស្ថាបនាជាតិ ១៩៥

### ២ – សេចក្ដីសំរេច

១៣ - ៥ - ១៩៩០ សេចក្ដីសំរេចលេខ ១០៥ សសរ ស្ដីពីការប្រគល់ភូមិក្រពាំងសង្កែ ... ឃុំគគីរធំ ស្រុកបាកាយ ខេត្តកំពង់ធំ ជូនខេត្តកំពង់ចាមគ្រប់គ្រង ១៩៧
២៦ - ៥ - ១៩៩០ សេចក្ដីសំរេចលេខ ១១៣ សសរ ស្ដីពីការកែប្រែចំពោះបន្ថែមលេខគណនីមួយចំនួននៅក្នុងប្រព័ន្ធគណនី នៃគណនេយ្យឯកភាព សំរាប់អនុវត្តតាមបណ្ដាអង្គភាព ១៩៨
២៧ - ៥ - ១៩៩០ សេចក្ដីសំរេចលេខ ១១៤ សសរ ស្ដីពីការចាត់តាំងបង្កើតស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែន និងផ្លូវគមនាគមន៍សំខាន់ៗ ទូទាំងប្រទេស ២០០
២៧ - ៥ - ១៩៩០ សេចក្ដីសំរេចលេខ ១១៥ សសរ ស្ដីពីតួនាទីភារកិច្ចរបស់ស្នាក់ការត្រួតពិនិត្យតាមបណ្ដាច្រកទ្វារព្រំដែន និងផ្លូវគមនាគមន៍សំខាន់ៗ ទូទាំងប្រទេស ២០៥
៣០ - ៥ - ១៩៩០ សេចក្ដីសំរេចលេខ ១២១ សសរ ស្ដីពីប្រព័ន្ធបៀវត្សរបស់កងកម្លាំងនគរបាល ២១០

Downloaded from http://www.khmerlaws.com

# I – ក្រុមប្រឹក្សារដ្ឋ

## ក្រឹត្យ

### ក្រឹត្យលេខ ៤៣ ក្រ

### ក្រុមប្រឹក្សារដ្ឋ

### នៃរដ្ឋកម្ពុជា

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សារដ្ឋ និង សមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី នាសម័យប្រជុំរដ្ឋសភាលើកទី ១៩ នីតិកាលទី ១ ។

## សំរេច

*មាត្រា ១* .— ត្រូវបានតែងតាំង

១ - ជារដ្ឋមន្ត្រីក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ សមមិត្ត រស់ ឈុន បច្ចុប្បន្នអគ្គលេខាធិការក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ជំនួសឈ្មោះ អ៊ុង ផន ដែលត្រូវបានរំសាយ ។

២ — ជារដ្ឋមន្ត្រីក្រសួងអប់រំ សមមិត្ត យស់ សុន បច្ចុប្បន្ន ប្រធានគណៈទាក់ទងបរទេសមជ្ឈិមបក្ស ជំនួស សមមិត្ត ប៉ែន ណាវុធ ដែលបានទទួលមរណភាព ។

៣ — ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល សមមិត្ត យឹម ឆៃលី បច្ចុប្បន្នអនុរដ្ឋមន្ត្រីក្រសួងសុខាភិបាល ជំនួស សមមិត្ត យិត គឹម សេង ។

៤ — ជារដ្ឋមន្ត្រីក្រសួងឃោសនាការ និង វប្បធម៌ សមមិត្ត ហង់ ជួន បច្ចុប្បន្នអនុរដ្ឋមន្ត្រីទី ១ ក្រសួងឃោសនាការ និង វប្បធម៌ ជំនួស សមមិត្ត ចេង ផុន ដែលត្រូវបានអនុញ្ញាតតាមសំណូមពរសុំសំរាកពីការងារ ។

Downloaded from http://www.khmerlaws.com

**មាត្រា ២ .—** ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងគមនាគមន៍ ដឹកជញ្ជូន និងប្រៃសណីយ៍ ក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងឃោសនាការ និង វប្បធម៌ ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩០*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

# ក្រឹត្យលេខ ៤៤ ក្រ

## ក្រុមប្រឹក្សារដ្ឋ

## នៃរដ្ឋកម្ពុជា

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សារដ្ឋ និង សមាជិកក្រុមប្រឹក្សារដ្ឋមន្ត្រី នាសម័យប្រជុំរដ្ឋសភាលើកទី ១៩ នីតិកាលទី ១

## សំរេច

**មាត្រា ១ .—** ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សារដ្ឋ សមមិត្ត ចែម ស្គួន បច្ចុប្បន្នអនុរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយរក្សាតួនាទីជាអនុរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដដែល ។

**មាត្រា ២ .—** ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩០*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

Downloaded from http://www.khmerlaws.com

# II- ក្រុមប្រឹក្សារដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

*ភ្នំពេញ , ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩០*

### អនុក្រឹត្យលេខ ១៩ អនក្រ
### ស្ដីពី ការបង្កើតមេដាយស្ថាបនាជាតិ

### *ក្រុមប្រឹក្សារដ្ឋមន្ត្រី*

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្ដីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ.ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញសំណូមពរចាំបាច់ នៃការលើកទឹកចិត្តចំពោះសប្បុរសជន ដែលបានរួមចំណែកក្នុងការស្ថាបនាជាតិមាតុភូមិ ។

### សំរេច

*មាត្រា ១* .— បង្កើត «មេដាយស្ថាបនាជាតិ » ដើម្បីជូនដល់សប្បុរសជនជាតិកម្ពុជា ជាសមូហភាព ឬ ជាបុគ្គលនៅក្នុង ឬ ក្រៅប្រទេស ដែលបានធ្វើអំណោយដល់រដ្ឋជាប្រាក់ ឬ ជាសម្ភារៈ ជួយស្ថាបនាជាតិ ។

*មាត្រា ២* .— « មេដាយស្ថាបនាជាតិ » មាន ៣ ថ្នាក់គឺ :

— មេដាយស្ថាបនាជាតិថ្នាក់លេខ ១ សំរាប់ជូនសប្បុរសជន ដែលបានធ្វើអំណោយដល់រដ្ឋជាប្រាក់ ឬ ជាសម្ភារៈមានតម្លៃពីរលានរៀលឡើងទៅ ។

— មេដាយស្ថាបនាជាតិថ្នាក់លេខ ២ សំរាប់ជូនសប្បុរសជនដែលធ្វើអំណោយដល់រដ្ឋជាប្រាក់ ឬ សម្ភារៈមានតម្លៃមួយលានរៀលឡើងទៅ ។

— មេដាយស្ថាបនាជាតិលេខ ៣ សំរាប់ជូនដល់សប្បុរសជន ដែលបានធ្វើអំណោយជាប្រាក់ ឬ ជាសំភារៈមានតម្លៃប្រាំរយពាន់រៀលឡើងទៅ ។

*មាត្រា ៣* .— « មេដាយស្ថាបនាជាតិ » គ្រប់ថ្នាក់ត្រូវសំរេចជូនដោយអនុក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

Downloaded from http://www.khmerlaws.com

*មាត្រា ៤* .— គ្រប់ក្រសួង - ស្ថាប័ន - គណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ពេលបាន ទទួលអំណោយស្ថាបនាជាតិពីសប្បុរសជន ដែលមានបរិមាណតិតជាប្រាក់ ដូចមានចែងក្នុងមាត្រា ២ ត្រូវធ្វើសំណើ និង របាយការណ៍ ស្តីពីគោលបំណង និង មុខសញ្ញាត្រូវកសាង - ស្ថាបនានៅមូលដ្ឋានរបស់ខ្លួន មកក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីពិនិត្យ និង សំរេច ។

*មាត្រា ៥* .— ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន អគ្គនាយកដ្ឋាន ព្រមទាំងគណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយបានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ជា សុទ្ធ

Downloaded from http://www.khmerlaws.com

## ២ - សេចក្តីសំរេច

*ភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩០*

# សេចក្តីសំរេចលេខ ១០៨ សសរ

## ស្តីពីការប្រគល់ភូមិត្រពាំងសង្កែ វាលស្ព
## វាលធំ របស់ឃុំ គគីរធំ ស្រុកបារាយ ខេត្តកំពង់ធំ
## ជូនខេត្តកំពង់ចាម គ្រប់គ្រង

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— ផ្អែកតាមសភាពការណ៍ចំពោះមុខ និងការឯកភាពរវាងខេត្តកំពង់ចាម ខេត្តកំពង់ធំ និងក្រសួងការពារប្រទេស

— យោងស្មារតីសំរេចរបស់គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩០

## សំរេច

*ប្រការ ១* : ប្រគល់ភូមិ ត្រពាំងសង្កែ វាលស្ព វាលធំ ក្នុងឃុំ គគីរធំ ស្រុកបារាយ ខេត្តកំពង់ធំ ជូនទៅខេត្តកំពង់ចាមគ្រប់គ្រង ។

— ចំពោះដី គឺមិនកាត់តាមខ្សែស្របរដ្ឋបាលទេ គ្រាន់តែផ្ទេរប្រជាជនប៉ុណ្ណោះ ។

— ព្រំប្រទល់រដ្ឋបាល គឺកាត់ពីចំណុច ស៊ុច ៦៨.៨៣ ស៊ីការ៉ិច ៣៣.៤០ ដូចមានក្នុងផែនទីជូនភ្ជាប់មកជាមួយ ។

*ប្រការ ២* : ខេត្តកំពង់ធំ ស្រុកបារាយ ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ក្នុងការផ្ទេរ ប្រគល់ភូមិទាំង ៣ ខាងលើនេះ ជូនទៅខេត្តកំពង់ចាមគ្រប់គ្រង អោយបានទាន់ពេលវេលា ។

Downloaded from http://www.khmerlaws.com

*ប្រការ ៣* : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម គណៈកម្មាធិការប្រជាជនខេត្តកំពង់ធំ កំពង់ចាម ត្រូវសហការអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់បំផុត ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

*ភ្នំពេញ ថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៩០*

# សេចក្តីសំរេចលេខ ១១៣ សសរ

## ស្តីពីការកែប្រែបំពេញបន្ថែមលេខគណនីមួយចំនួន នៅក្នុងប្រព័ន្ធគណនីនៃគណនេយ្យឯកភាពសំរាប់ អនុវត្តតាមបណ្តាអង្គភាពសេដ្ឋកិច្ចរដ្ឋ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញសេចក្តីសំរេចលេខ ៤៩ សសរ ចុះថ្ងៃទី ១១ មេសា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

– តាមសំណើរបស់សមមិត្ត រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

## សំរេច

*មាត្រា ១* – កែប្រែ និង បំពេញបន្ថែមលេខគណនីមួយចំនួនរបស់ប្រព័ន្ធគណនី នៃគណនេយ្យឯកភាពសំរាប់អនុវត្តនៅបណ្តាផ្នែកសេដ្ឋកិច្ចរដ្ឋដូចខាងក្រោម៖

*ប្រភេទ V : ខុនជាប្រាក់*

Downloaded from http://www.khmerlaws.com

– បេឡាសាច់ប្រាក់ : គណនី ៥០

– ៥០.១ : ជាប្រាក់រៀល

– ៥០.២ : ជារូបិយប័ណ្ណ

– *ប្រាក់ផ្ញើធនាគារ* : គណនី ៥១

– ៥១.១ : ប្រាក់ផ្ញើធនាគារជាប្រាក់រៀល

– ៥១.២ : ប្រាក់ផ្ញើធនាគារជារូបិយប័ណ្ណ

« ក្រោពីនេះនៅក្នុងប្រភេទ គ្មានអ្វីកែប្រែទេ »

*ប្រភេទ VI : ទូទាត់*

– ទូទាត់ធានារ៉ាប់រងសង្គម : គណនី ៦៨

– ៦៨.១ : ធានារ៉ាប់រងទុកអោយសហគ្រាស

– ៦៨.២ : ធានារ៉ាប់រងបង់ចូលថវិការដ្ឋ

– *ទូទាត់ជាមួយថវិកា* : គណនី ៧១

– ៧១.១ : ពន្ធលើផលរបរ

– ៧១.២ : ពន្ធលើប្រាក់ចំណេញ

– ៧១.៣ : ពន្ធលើទំនិញក្នុងប្រទេស

– ៧១.៤ : ពន្ធប៉ាតង់

– ៧១.៥ : បង់កំរៃទុន « ចំណូលលើ-ទុនផលិត

– ៧១.៦ : ខ្ទង់ចំណូលផ្សេង ៗ

« ក្រោពីនេះ នៅក្នុងប្រភេទ VI គ្មានអ្វីកែប្រែទេ »

*ប្រភេទ VII : ទុនផក*

– *ទុនផក* : គណនី ៨០

– ៨០.១ : ផកបង់ប្រាក់ចំណេញ

– ៨០.២ : ផកបង្កើតមូលនិធិថ្លែងសរសើរ

– ៨០.៣ : ផកបង្កើតមូលនិធិបំរុង

– ៨០.៤ : ផកដើម្បីបង់កំរៃទុន

Downloaded from http://www.khmerlaws.com

— ៩០.៥ : ទុនផលផ្សេងៗ ។

" ទុនផលក្រោពីនេះ លុបចោល "

*ប្រភេទ VIII : ប្រភពទុន*

*- មូលនិធិសហគ្រាស :* គណនី ៩៨

— ៩៨.១ : មូលនិធិថ្លែងសរសើរជូនរង្វាន់

— ៩៨.២ : មូលនិធិបំរុង

— ៩៨.៣ : មូលនិធិផ្សេង ។

" ក្រៅពីនេះលប់ចោល "

*មាត្រា ២ .—* ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ បណ្ដាក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ គណៈកម្មាធិការប្រជាជនខេត្ត – ក្រុង មានភារកិច្ច អនុវត្តតាមសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ចា ស៊ុន

*ភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩០*

# សេចក្ដីសំរេច លេខ ១១៨ សសរ

## ស្ដីពីការចាត់តាំងបង្កើតស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែន និង ផ្លូវគមនាគមន៍សំខាន់ៗទូទាំងប្រទេស

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ស្ដីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ១៣ ក្រ ចុះថ្ងៃទី ១០ កុម្ភៈ ឆ្នាំ ១៩៨២

Downloaded from http://www.khmerlaws.com

– ផ្អែកតាមសម័យប្រជុំពេញអង្គក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ៥-៦-៧ ខែ មេសា ឆ្នាំ ១៩៩០

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគមនាគមន៍ ។

## សំរេច

*ប្រការ ១* : ចាត់តាំងបង្កើតឡើងវិញ បណ្ដាស្នាក់ការត្រួតពិនិត្យនៅតាមផ្លូវគមនាគមន៍ និងតាមច្រកទ្វារសំខាន់ៗ នៃផ្លូវគោក ផ្លូវទឹក ផ្លូវដែក ផ្លូវសមុទ្រ ផ្លូវអាកាស ទូទាំងប្រទេសរួមមាន :

ក – បណ្ដាស្នាក់ការត្រួតពិនិត្យចេញ ចូលច្រកទ្វារព្រំដែន ដែលឋិតនៅក្រោមការគ្រប់គ្រង និង ដឹកនាំផ្ទាល់របស់មជ្ឈិមរួមមាន :

*១ - ខេត្តស្វាយរៀង* :

- ស្នាក់ការត្រួតពិនិត្យផ្លូវគោក បាវិត

*២ - ខេត្តកណ្ដាល* :

- ស្នាក់ការត្រួតពិនិត្យផ្លូវគោក - ទឹក ក្អមសំណរ កោះរការ

- ស្នាក់ការត្រួតពិនិត្យផ្លូវគោក - ទឹក ព្រែកជ្រៃធំ ខ្នាតរាំងយូ

*៣ - ខេត្តកំពង់ចាម* :

- ស្នាក់ការត្រួតពិនិត្យផ្លូវគោក ត្រពាំងផ្លុង

*៤ - ខេត្តស្ទឹងត្រែង* :

- ស្នាក់ការត្រួតពិនិត្យផ្លូវគោក ដុំក្រឡ

- ស្នាក់ការត្រួតពិនិត្យផ្លូវទឹក យឺណាក

*៥ – ខេត្តបន្ទាយមានជ័យ* :

– ស្នាក់ការត្រួតពិនិត្យផ្លូវគោក - ដែក ទឹកថ្លា និង កូនដំរី " ស្រុកសេរីសោភ័ណ "

*៦ – ខេត្តកោះកុង* :

– ស្នាក់ការត្រួតពិនិត្យផ្លូវសមុទ្រ ចាក់ខ្លុង

– ស្នាក់ការត្រួតពិនិត្យផ្លូវគោក នាងកុក មណ្ឌលសីមា

Downloaded from http://www.khmerlaws.com

— ស្នាក់ការត្រួតពិនិត្យព្រលានយន្តហោះខេមរៈភូមិន្ទខេត្តកោះកុង

៧ — ក្រុងកំពង់សោម

— ស្នាក់ការត្រួតពិនិត្យកំពង់ផែ កំពង់សោម

— ស្នាក់ការត្រួតពិនិត្យផ្លូវសមុទ្រ ទំនប់រលក

៨ — ខេត្តកំពត :

— ស្នាក់ការត្រួតពិនិត្យផ្លូវសមុទ្រ កែប

៩ — ខេត្តតាកែវ :

— ស្នាក់ការត្រួតពិនិត្យផ្លូវគោក ភ្នំដិន

១០ — ខេត្តសៀមរាប :

— ស្នាក់ការត្រួតពិនិត្យព្រលានយន្តហោះ

១១ — រដ្ឋធានីភ្នំពេញ :

— ស្នាក់ការត្រួតពិនិត្យ ព្រលានយន្តហោះពោធិចិនតុង

— ស្នាក់ការត្រួតពិនិត្យកំពង់ផែ ក្រុងភ្នំពេញ

១២ — ខេត្តកំពង់ស្ពឺ :

— ស្នាក់ការត្រួតពិនិត្យផ្លូវគោក ត្រែងត្រយឹង

ខ — បណ្តាស្នាក់ការត្រួតពិនិត្យច្រកចេញ ចូល តាមព្រំដែន ដែលឋិតនៅក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់របស់មូលដ្ឋានខេត្ត - ក្រុង រួមមាន :

១ - ខេត្តស្វាយរៀង :

— ស្នាក់ការត្រួតពិនិត្យផ្លូវគោក ព្រៃវល្លិ៍

— ស្នាក់ការត្រួតពិនិត្យផ្លូវគោក បុសមន

២ — ខេត្តព្រៃវែង :

— ស្នាក់ការត្រួតពិនិត្យផ្លូវទឹក ទាបន្ទា

— ស្នាក់ការត្រួតពិនិត្យផ្លូវទឹក កោះសំពៅ

៣ - ខេត្តកំពង់ចាម :

— ស្នាក់ការត្រួតពិនិត្យផ្លូវគោក ដា

— ស្នាក់ការត្រួតពិនិត្យផ្លូវគោក ដរក្រូវៀន « ស្រុកមេមត់ »

Downloaded from http://www.khmerlaws.com

៤ — ខេត្តតាកែវ :

— ស្ថានីយការត្រួតពិនិត្យផ្លូវទឹក កំពង់ក្រសាំង

— ស្ថានីយការត្រួតពិនិត្យផ្លូវទឹក ជាក់ដៃ

៥ - ខេត្តកំពត :

— ស្ថានីយការត្រួតពិនិត្យផ្លូវគោក ទន់ហន់

— ស្ថានីយការត្រួតពិនិត្យផ្លូវគោក- សមុទ្រ ព្រែកចាក " សក "

— ស្ថានីយការត្រួតពិនិត្យផ្លូវទឹក- សមុទ្រ កោះសេះ

— ស្ថានីយការត្រួតពិនិត្យផ្លូវសមុទ្រ ទីរួមខេត្ត

— ស្ថានីយការត្រួតពិនិត្យផ្លូវគោក- សមុទ្រ ត្រពាំងល្ពៅ

៦ - ក្រុងកំពង់សោម

— ស្ថានីយការត្រួតពិនិត្យផ្លូវគោក- សមុទ្រ ស្ទឹងហាវ

— ស្ថានីយការត្រួតពិនិត្យស្ថានីយ៍រថភ្លើង ក្រុងកំពង់សោម

៧ — ខេត្តកោះកុង :

- ស្ថានីយការត្រួតពិនិត្យផ្លូវសមុទ្រ កោះស្ដេច

- ស្ថានីយការត្រួតពិនិត្យផ្លូវសមុទ្រ ស្រែអំបិល

— ស្ថានីយការត្រួតពិនិត្យផ្លូវសមុទ្រ ថ្មស

— ស្ថានីយការត្រួតពិនិត្យផ្លូវគោក អូរជ្រៅ

៨ — រដ្ឋធានីភ្នំពេញ :

— ស្ថានីយការត្រួតពិនិត្យស្ថានីយ៍រថភ្លើង តាំងក្រសាំង

៩ — ខេត្តកំពង់ឆ្នាំង :

— ស្ថានីយការត្រួតពិនិត្យផ្លូវទឹក ឆ្នុកទ្រូ

១០ — ខេត្តមណ្ឌលគិរី :

— ស្ថានីយការត្រួតពិនិត្យផ្លូវគោក ស្រុកកែវសីមា

១១ — ខេត្តរតនៈគិរី :

- ស្ថានីយការត្រួតពិនិត្យផ្លូវគោក អូរយ៉ាដាវ

- ស្ថានីយការត្រួតពិនិត្យផ្លូវទឹក ទន្លេសេសាន

Downloaded from http://www.khmerlaws.com

*១២ – ខេត្តក្រចេះ :*

– ស្នាក់ការត្រួតពិនិត្យផ្លូវគោក ស្នួល

គ – បណ្តាស្នាក់ការត្រួតពិនិត្យ រក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គមរួមមាន

– *រដ្ឋធានីភ្នំពេញ :*

– ស្នាក់ការត្រួតពិនិត្យផ្លូវគោក ចោមចៅ

– ស្នាក់ការត្រួតពិនិត្យផ្លូវគោក-ទឹក ព្រែកព្នៅ

- ស្នាក់ការត្រួតពិនិត្យផ្លូវទឹក ក្បាលជ្រោយ

*២. ខេត្តបាត់ដំបង*

- ស្នាក់ការត្រួតពិនិត្យផ្លូវគោក អណ្តូងចេញ

*ប្រការ ២* : បណ្តាស្នាក់ការត្រួតពិនិត្យ រក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម គឺជាស្នាក់ការត្រួតពិនិត្យឋិតក្រោមការគ្រប់គ្រងផ្ទាល់របស់មូលដ្ឋានខេត្ត - ក្រុង ដោយឡែកស្នាក់ការត្រួតពិនិត្យការពារព្រំដែនទន្លេសាប គឺអាស្រ័យដោយក្រសួងមហាផ្ទៃ ក្រសួងការពារប្រទេស ក្រសួងកសិកម្មគ្រប់គ្រងដឹកនាំផ្ទាល់ ។

*ប្រការ ៣* : ការកំណត់ដាក់បន្ថែម ឬ ដកចេញនូវស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារចេញ-ចូលតាមផ្លូវគមនាគមន៍សំខាន់ៗ និងស្នាក់ការការពាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមក្នុងទូទាំងប្រទេស គឺអាស្រ័យដោយក្រុមប្រឹក្សារដ្ឋមន្ត្រីពិនិត្យ និង សំរេច ។

*ប្រការ ៤* : បណ្តាស្នាក់ការត្រួតពិនិត្យ និង ក្រុមចល័តណា ដែលមូលដ្ឋានបានបង្កើតឡើងដោយឯកឯង គ្មានសេចក្តីសំរេចពីក្រុមប្រឹក្សារដ្ឋមន្ត្រី គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងនោះត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សារដ្ឋមន្ត្រី ។

*ប្រការ ៥* : សេចក្តីសំរេចលេខ ១៤៨ សសរ.ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទុកជានិរាករណ៍ ។

*ប្រការ ៦* : រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងគមនាគមន៍ ដឹកជញ្ជូន និង

Downloaded from http://www.khmerlaws.com

ប្រៃណីយ៍គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង និងគណៈកម្មការចំរុះត្រួតពិនិត្យស្នាក់ការ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

ភ្នំពេញថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩០

# សេចក្ដីសំរេចលេខ ១១៩ សសរ

## ស្ដីពីតួនាទីភារកិច្ចរបស់ស្នាក់ការត្រួតពិនិត្យ តាមបណ្ដាច្រកទ្វារព្រំដែន និងផ្លូវគមនាគមន៍ សំខាន់ៗទូទាំងប្រទេស

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្ដីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ. ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– ផ្អែកតាមសម័យប្រជុំពេញអង្គក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ៥-៦-៧ ខែ មេសា ឆ្នាំ ១៩៩០

– តាមសំណើរបស់ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង រដ្ឋមន្ត្រីក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

## សំរេច

*ប្រការ ១ : អំពីសមាសភាព*

ក. កម្លាំងដែលមានតួនាទី ភារកិច្ចត្រួតពិនិត្យនៅតាមស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនត្រូវបានកំណត់ដូចខាងក្រោម :

Downloaded from http://www.khmerlaws.com

១ - កម្លាំងនគរបាលចំណុះក្រសួងមហាផ្ទៃ ជាប្រធាន

២ - កម្លាំងយោធាចំណុះក្រសួងការពារប្រទេស ជាអនុប្រធាន

៣- ភ្នាក់ងារជំនាញចំណុះក្រសួងហិរញ្ញវត្ថុ ជាសមាជិក

៤ - ភ្នាក់ងារជំនាញចំណុះក្រសួងកសិកម្ម ជាសមាជិក

៥ - ភ្នាក់ងារជំនាញចំណុះក្រសួងពាណិជ្ជកម្ម ជាសមាជិក

៦ - ភ្នាក់ងារជំនាញចំណុះក្រសួងសុខាភិបាល ជាសមាជិក

៧ - ភ្នាក់ងារជំនាញចំណុះក្រសួងគមនាគមន៍ ជាសមាជិក

សមាសភាពខាងលើអាចមាន ឬ មិនមាន គឺ អាស្រ័យដោយ គណៈកម្មការចំរុះ ត្រួតពិនិត្យស្នាក់ការត្រួតពិនិត្យសំរេចតាមសំណើរបស់សាមីក្រសួង ។

ខ- កងកម្លាំងនៅបណ្តាស្នាក់ការត្រួតពិនិត្យ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខេត្តក្រុងរួមមាន :

១- កម្លាំងនគរបាលចំណុះមន្ទីរនគរបាល ជាប្រធាន

២ - កម្លាំងយោធាចំណុះអង្គភាពយោធា ជាអនុប្រធាន

៣- ភ្នាក់ងារជំនាញរបស់មន្ទីរហិរញ្ញវត្ថុ ជាសមាជិក

៤ - ភ្នាក់ងារជំនាញរបស់មន្ទីរកសិកម្ម ជាសមាជិក

សមាសភាពខាងលើអាចមាន ឬ មិនមានគឺអាស្រ័យដោយគណៈកម្មាធិការប្រជាជនខេត្ត - ក្រុងសំរេច ។

គ - កម្លាំងដែលមានតួនាទី ភារកិច្ចត្រួតពិនិត្យ នៅតាមស្នាក់ការត្រួតពិនិត្យរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងរក្សាការពារបឹងទន្លេសាបរួមមាន :

១- កម្លាំងនគរបាល ជាប្រធាន

២- កម្លាំងយោធា ជាអនុប្រធាន

– បណ្តាកម្លាំងដែលមានតួនាទី ភារកិច្ចនៅតាមស្នាក់ការត្រួតពិនិត្យ រក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម គឺអាស្រ័យដោយមូលដ្ឋានខេត្ត-ក្រុង សំរេច ដោយតែមានកងកម្លាំងប្រដាប់អាវុធ រីឯកម្លាំងការពារបឹងទន្លេសាប អាស្រ័យដោយក្រសួងមហាផ្ទៃ ក្រសួងការពារប្រទេស និងក្រសួងកសិកម្ម ពិនិត្យសំរេច ។

– ចំពោះកម្មាភិបាល យុទ្ធជន បុគ្គលិក ដែលបានជ្រើសរើសចាត់តាំង ដោយទៅបំពេញភារកិច្ចនៅតាមស្នាក់ការត្រួតពិនិត្យនីមួយៗ គឺត្រូវបានប្រវត្តិរូបត្រឹមត្រូវ ច្បាស់លាស់ និងបាន

Downloaded from http://www.khmerlaws.com

ឆ្លងកាត់វគ្គមុខជំនាញ មានអាកប្បកិរិយាគោរពវិន័យល្អ សមស្របជាកូនចៅរបស់ប្រជាជនពិត ។ និង ជាអ្នកបំរើផលប្រយោជន៍ស្របច្បាប់របស់ប្រជាជន ។

*ប្រការ ២ អំពីតួនាទី ភារកិច្ច :*

ក- ភារកិច្ចត្រួតពិនិត្យរបស់ស្នាក់ការត្រួតពិនិត្យនីមួយៗគឺត្រូវធានាការចូលរួមចំណែកយ៉ាងសំខាន់ដល់កិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម គ្រប់គ្រងសេដ្ឋកិច្ចជាតិ និងសំរួលចរាចរដឹកជញ្ជូន ធ្វើដំណើរទៅមករបស់ប្រជាជន ។

ខ- ភារកិច្ចជាក់ស្តែងរបស់បណ្តាកម្លាំងនីមួយៗ ដែលមានតួនាទី ភារកិច្ចត្រួតពិនិត្យនៅតាមស្នាក់ការត្រួតពិនិត្យរួមមាន :

១- កម្លាំងនគរបាលទទួលខុសត្រូវរួម មានភារកិច្ចគ្រប់គ្រងត្រួតពិនិត្យរាល់ការចេញ ចូល ឆ្លងកាត់ទៅមកនៃជនស៊ីវិល នគរបាល ជាតិផ្ទុះ មធ្យោបាយ សម្ភារៈទំនិញ លិខិតស្នាមដែលមានពាក់ព័ន្ធសន្តិសុខ នយោបាយ សណ្តាប់ធ្នាប់សង្គមនៅតាមច្រកទ្វារព្រំដែន ធានាកិច្ចសហប្រតិបត្តិការអោយបានឯកភាពគ្នា នូវរាល់ផែនការ វិធានការ សកម្មភាពរបស់បណ្តាកម្លាំងក្នុងស្នាក់ការត្រួតពិនិត្យ ដើម្បីអនុវត្តអោយបានម៉ឺងម៉ាត់ ត្រឹមត្រូវតាមភារកិច្ច មុខជំនាញនីមួយៗ របស់ខ្លួន ។

២- កម្លាំងយោធាជាអ្នកទទួលខុសត្រូវរួម ពេលប្រធានស្នាក់ការត្រួតពិនិត្យ .. នគរបាលអវត្តមាន និងមានភារកិច្ចត្រួតពិនិត្យរាល់យោធិន អាវុធ ជាតិផ្ទុះ មធ្យោបាយសម្ភារៈ យោធាដែលឆ្លងកាត់ចេញ ចូល តាមច្រកទ្វារព្រំដែន ហើយមានការចាត់តាំងបណ្តាកម្លាំងក្នុងស្នាក់ការត្រួតពិនិត្យ ដើរល្បាតត្រួតពិនិត្យការពារជុំវិញភូមិសាស្ត្រស្នាក់ការត្រួតពិនិត្យ ទោះបីយប់ថ្ងៃ នៅតាមបណ្តាព្រំដែនដែលបានប្រគល់អោយ ដឹកនាំធ្វើជាប្រធានបញ្ជាការឯកភាព ។

៣- ភ្នាក់ងារអាកាសចរមានភារកិច្ចការពារ និង គ្រប់គ្រងថែរក្សាទាំងស្រុងនូវមូលដ្ឋានសម្ភារៈ បច្ចេកទេស បរិក្ខាររបស់ស្ថាប័នអាកាសចរស៊ីវិល ប្រព័ន្ធផ្លូវឡើងចុះ ចំណតយន្តហោះ កន្លែងយន្តហោះចតប្រមូលផ្តុំ និងអ្នកដំណើរចេញចូលតាមព្រលានយន្តហោះ ។

៤- ភ្នាក់ងារគយមានភារកិច្ចត្រួតពិនិត្យមុខទំនិញ ឥវ៉ាន់អ្នកដំណើរ អំណោយរូបិយប័ណ្ណ រូបិយវត្ថុជាតិ លោហធាតុមានតម្លៃ ត្បូងថ្មមានតម្លៃ កញ្ចប់ ឬហិបប្រៃសណីយ៍ មធ្យោបាយគ្រប់ប្រភេទ ហើយប្រមូលពន្ធនាំចេញ ចូល និង ប្រឆាំងរាល់អំពើរត់ពន្ធដែលឆ្លងកាត់តំបន់ព្រំដែន ។

៥- ភ្នាក់ងារពន្ធដារនិងស្បៀងអាហារពាណិជ្ជ មានភារកិច្ចត្រួតពិនិត្យ និងគ្រប់គ្រងប្រមូលពន្ធតាម

Downloaded from http://www.khmerlaws.com

ក្រឹត្យច្បាប់ពន្ធលើមុខទំនិញ ដែលពុំទាន់បង់ពន្ធគ្រប់គ្រាន់ ឬមិនទាន់បង់ពន្ធ ដែលធ្វើចរាចរឆ្លងកាត់មកស្នាក់ការត្រួតពិនិត្យ ។

៦- ភ្នាក់ងាររុក្ខាប្រមាញ់មានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យអនុផលព្រៃឈើដែលឆ្លងកាត់ចេញ ចូល តាមព្រំដែន ។

៧- ភ្នាក់ងារជលផលមានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យផល នេសាទដែលឆ្លងកាត់ចេញ ចូល តាមព្រំដែន ។

៨- ភ្នាក់ងារភូតគាមអនាម័យមានភារកិច្ចត្រួតពិនិត្យ រកឃើញរាំងស្កាត់រាល់ប្រភេទជំងឺឆ្លង ដែលនៅលើធញ្ញជាតិ រុក្ខជាតិឬនៅលើសត្វ ផលិតផលនៃសត្វដែលចរាចរឆ្លងកាត់មកតាមព្រំដែន ។

៩- ភ្នាក់ងារកាកុងត្រូលមានភារកិច្ចត្រួតពិនិត្យរាល់មុខទំនិញនាំចេញ នាំចូលមានអាជ្ញាប័ណ្ណ " នាំចេញ នាំចូល " ដែលឆ្លងកាត់តាមច្រកទ្វារព្រំដែន ។

១០- ភ្នាក់ងារកវ៉ាសាបមានភារកិច្ចទទួលរ៉ាប់រងទំនាក់ទំនងការងារបែបបទរដ្ឋបាលដោយនាវា ។ សម្រួលការងារទំនាក់ទំនង និងគណៈកម្មការបែបបទ ។

១១- ភ្នាក់ងារចត្តាឡីសក្តិមានភារកិច្ចត្រួតពិនិត្យ រកឃើញ និងបង្ការគ្រប់ប្រភេទ នូវជំងឺឆ្លងទាំងឡាយដែលផាប់ពីមូលដ្ឋានមួយទៅមូលដ្ឋានមួយ និងពីប្រទេសមួយទៅប្រទេសមួយដោយឆ្លងកាត់តាមតំបន់ចត្តាឡីសក្តិអោយបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋ និងបទបញ្ញាសុខាភិបាលអន្តរជាតិ ។

- កម្លាំងទាំងអស់អនុវត្តភារកិច្ចទៅតាមមុខនាទីរបស់ខ្លួន តែត្រូវសកម្មភាពដោយសហប្រតិបត្តិការ ។ មិនអនុញ្ញាតអោយសកម្មភាពដោយឡែកៗពីគ្នា ។

*ប្រការ ៣:* ធនាគារជាតិ នៃប្រជាជនកម្ពុជា ត្រូវបង្កលក្ខណៈងាយស្រួលអោយស្នាក់ការត្រួតពិនិត្យទាំងឡាយដែលមានសំណូមពរចាំបាច់ក្នុងការផ្ញើប្រាក់ រូបិយប័ណ្ណ រូបិយវត្ថុលោហធាតុ និងត្បូងថ្មមានតម្លៃអោយបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋ ។

*ប្រការ ៤:* គ្រប់កងកម្លាំងដែលមានចែងក្នុងប្រការ ១ ប្រការ ២ ត្រូវមានមុខប្រតិបត្តិការ ២៤ ម៉ោង លើ ២៤ ម៉ោង ហើយធានាកម្លាំងគ្រប់ចំនួន ១០០ ភាគរយនៅស្នាក់ការត្រួតពិនិត្យ អនុវត្តអោយបានត្រឹមត្រូវ នូវមុខងារ ភារកិច្ចរបស់ខ្លួនដែលបានកំណត់ គ្រប់

Downloaded from http://www.khmerlaws.com

កម្លាំងទាំងអស់ត្រូវប្រមូលផ្តុំសហការគ្នាទាំងស្មារតី និងសម្ភារៈអោយបានល្អ ដើម្បីធានាមុខជំនាញ និងជីវភាពស្នាក់នៅ ។

*ប្រការ ៥:* បុគ្គលិក និង អង្គភាពដែលអនុវត្តបានត្រឹមត្រូវល្អតាមសេចក្តីសំរេចនេះ ត្រូវទទួលបាននូវការសរសើរជូនរង្វាន់លើកទឹកចិត្ត ។ ចំពោះបុគ្គលនិងអង្គភាពណាដែលអនុវត្តមិនត្រឹមត្រូវ ខុសឆ្គងនឹងសេចក្តីសំរេចនេះ ផ្អែកទៅតាមកំរិតស្រាល ឬធ្ងន់ ត្រូវអនុវត្តវិន័យ ឬ ផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

*ប្រការ ៦ :* សេចក្តីសំរេចលេខ ១៨៧ សសរ, ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៨៧ ស្តីពីតួនាទីភារកិច្ចរបស់ស្នាក់ការត្រួតពិនិត្យតាមផ្លូវគមនាគមន៍សំខាន់ៗ ទូទាំងប្រទេស ចាត់ទុកជានិរាករណ៍ ។

*ប្រការ ៧ :* រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងគមនាគមន៍ដឹកជញ្ជូន និងប្រៃសណីយ៍ គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង និងគណៈកម្មការចំរុះត្រួតពិនិត្យស្នាក់ការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវផ្អែកតាមតួនាទី ភារកិច្ចមុខជំនាញរៀងៗខ្លួន ចាត់តាំងអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ចាប់ ពីថ្ងៃចុះហត្ថលេខា និងរាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សារដ្ឋមន្ត្រី។

ជ· ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

Downloaded from http://www.khmerlaws.com

ភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩០

# សេចក្តីសំរេច លេខ ១២១ សសរ

## ស្តីពីប្រព័ន្ធបៀវត្សរបស់កងកម្លាំងនគរបាល

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញក្រឹត្យ-ច្បាប់លេខ ៤០ ក្រច ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៨៨ ស្តីពីឋានន្តរៈសក្តិរបស់កងកម្លាំងនគរបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

*ប្រការ ១* : កំណត់រៀបចំប្រព័ន្ធបៀវត្សថ្មីរបស់នាយនគរបាល នាយនគរបាលរង ពលនគរបាល នគរបាលបច្ចេកទេសជំនាញ និង កម្មករនគរបាល ដើម្បីលើកកំពស់ជីវភាព និង ស្មារតីប្រយុទ្ធរបស់កងកម្លាំងនគរបាល ។

*ប្រការ ២* : បៀវត្សសុទ្ធសាធ របស់នាយនគរបាល នាយនគរបាលរង និងពលនគរបាល គឺជាបៀវត្សឋានន្តរៈសក្តិរួមមាន : ប្រាក់បំណាច់លើមុខតំណែងបូក នឹង ប្រាក់បំណាច់ឋានន្តរៈសក្តិ ។

ក - ប្រាក់បំណាច់លើមុខតំណែងរបស់នាយនគរបាល នាយនគរបាលរង និងពលនគរបាលរួមមាន ១៤ ថ្នាក់ គឺ ចាប់ពីថ្នាក់រដ្ឋមន្ត្រី ដល់ យុទ្ធជន ។

" តារាង ក១ ជូនជាប់ "

ចំពោះមុខតំណែងប្រហាក់ប្រហែលផ្សេងទៀត ដែលគ្មានចែងក្នុងតារាងក១ នេះ គឺ ប្រគល់សិទ្ធិអោយក្រសួងមហាផ្ទៃកំណត់ និង រៀបចំបន្ថែម ដោយផ្អែកលើភារកិច្ចទទួលខុសត្រូវ នៃមុខតំណែងនីមួយៗ ។

– ប្រាក់បំណាច់ឋានន្តរៈសក្តិរបស់នាយនគរបាល នាយនគរបាលរង និង ពលនគរបាលរួមមាន ១៥ ថ្នាក់ គឺ ចាប់ពីថ្នាក់ឧត្តមសេនីយឯក ដល់ ពលទោ ។

" តារាង ក២ ជូនជាប់ "

Downloaded from http://www.khmerlaws.com

ចំពោះប្រាក់បំណាច់បានន្តសក្តិ ត្រូវអនុវត្តចាប់ពីខែ មករា ឆ្នាំ ១៩៩០ ។

*ប្រការ ៣* : ចំពោះនគរបាលបច្ចេកទេសជំនាញ និង កម្មករនគរបាល :

ក – នគរបាលបច្ចេកទេសជំនាញ ៖

បៀវត្សរបស់នគរបាលបច្ចេកទេសជំនាញ ស្ថិតក្នុងក្របខ័ណ្ឌកម្លាំងនគរបាល ត្រូវកំណត់ក្នុងតារាង ១១-១២-១៣ នៃប្រព័ន្ធបៀវត្សផ្នែកស៊ីវិល ។ ដោយឡែកបៀវត្សប្រភេទ ១៤ មិនត្រូវបានរៀបចូលក្នុងតារាងបៀវត្សរបស់នគរបាលបច្ចេកទេសជំនាញឡើយ គឺត្រូវរៀបចូលក្នុងតារាង ក១ វិញ ។

" តារាង ខ ជូនជាប់ "

ខ – កម្មករនគរបាល ត្រូវបានធានាប្រាក់បៀវត្សតាមមុខជំនាញឯកទេសតាមលក្ខណៈពលកម្មដែលកំណត់ក្នុងតារាង គ នៃប្រព័ន្ធបៀវត្សផ្នែកស៊ីវិល

– នគរបាលបច្ចេកទេសជំនាញ និង កម្មករនគរបាល ត្រូវបានចំពាក់បានន្តរៈសក្តិបច្ចេកទេសទទួលប្រាក់បំណាច់បានន្តរៈសក្តិ តាមតារាង ក២ និងផលប្រយោជន៍ផ្សេងទៀត ដូចកងកម្លាំងនគរបាលដែលធ្វើការរួមនៅក្នុងអង្គភាពដែរ ។

– ការធ្វើកម្មសិក្សារបស់នគរបាលបច្ចេកទេសជំនាញ និង កម្មករនគរបាល ត្រូវអនុវត្តដូចផ្នែកស៊ីវិល ។

*ប្រការ ៤* : កងកម្លាំងនគរបាល ត្រូវបានទទួលប្រាក់អតីតភាព ចាប់ពី ៥ ភាគរយ ដល់ ៤០ ភាគរយ ដោយគិតតាមរយៈពេលបំរើការងារក្នុងកងកម្លាំងនគរបាល ។

ប្រាក់អតីតភាពនេះត្រូវបានគិតគូរលើបៀវត្សសុទ្ធសាធ ។

" តារាង ឃ ជូនជាប់ "

*ប្រការ ៥* : កងកម្លាំងនគរបាលត្រូវបានធានាទទួលស្រង់ នូវបណ្តារយោធបរិក្ខារ ដែលកំណត់ដោយក្រសួងមហាផ្ទៃ សំរាប់បំរើសំណុមពរភារកិច្ច និង បំពេញការងារប្រយុទ្ធ ។

*ប្រការ ៦ : អំពីរបបឧបត្ថម្ភ :*

ក – ប្រាក់ហូបគឺជាចំនួនប្រាក់ឯកភាព ដែលបានកំណត់ ក្រៅពីបៀវត្សសុទ្ធសាធរបស់នាយនគរបាល នាយនគរបាលរង ពលនគរបាល នគរបាលបច្ចេកទេសជំនាញ និង កម្មករនគរបាល ។

Downloaded from http://www.khmerlaws.com

— ប្រាក់ហូបនេះ ត្រូវបានកំណត់ ទំនិញ តារាងតាមសេចក្តីសំរេចលេខ ៦៣ សសរ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៤ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលមានចែកជា ២ កំរិតខុសគ្នា :

— កំរិត ១ : សំរាប់កម្មាភិបាលជាន់ខ្ពស់ ក្នុង ១ ថ្ងៃ ១ នាក់ ៥,០០

— កំរិត ២ : សំរាប់កម្មាភិបាលមធ្យម ក្នុង ១ ថ្ងៃ ១ នាក់ ៤,៥០

តែចំនួនប្រាក់ហូបនេះ ត្រូវតែសំរួលតាមការឯកភាព រវាងក្រសួងមហាផ្ទៃ ក្រសួងហិរញ្ញវត្ថុ និងក្រសួងផែនការ ក្នុងករណីដែលថ្លៃទំនិញមានការប្រែប្រួលមិនអាចធានាការហូបចុកបានគ្រប់គ្រាន់ ។

• ខ — កងកម្លាំងនគរបាល ដែលបានច្បាប់អនុញ្ញាតអោយទៅសំរាកចំបិនសុខភាពនៅតាមមណ្ឌលសុខភាព ត្រូវបានក្រសួងមហាផ្ទៃពិនិត្យផ្តល់ប្រាក់ម្ហូបបន្ថែមអោយបានសមស្របតាមការជាក់ស្តែង ។

គ — កងកម្លាំងនគរបាល ត្រូវបានទទួលប្រាក់ឧបត្ថម្ភ សំរាប់បំពេញការហូបចុកនៅពេលកំពុងសិក្សា ហ្វឹកហាត់នៅក្នុងសាលា តាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

ឃ - កងកម្លាំងនគរបាល ត្រូវបានទទួលការឧបត្ថម្ភបន្លែស្រស់ ត្រីស្រស់ ២៥៥ រៀល ក្នុង ១ ខែ ក្នុងមួយនាក់ ។ ប្រាក់ឧបត្ថម្ភនេះ ត្រូវបានកែសំរួលមួយដង ក្នុងមួយឆ្នាំ តាមតម្លៃជាក់ស្តែង តាមការឯកភាពពីក្រសួងហិរញ្ញវត្ថុ ។

ង - កងកម្លាំងនគរបាល ត្រូវបានទទួលប្រាក់ហូបបន្ថែមតាមប្រភេទជំនាញនគរបាលតាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

ច - កងកម្លាំងនគរបាល ត្រូវបានទទួលប្រាក់បំណាច់ប្រយុទ្ធ ១០ ភាគរយ លើបៀវត្សសុទ្ធសាធ តែមុខសញ្ញា និង សមាសភាពដែលត្រូវបាននោះ គឺ អាស្រ័យដោយក្រសួងមហាផ្ទៃកំណត់ ។

ឆ - ផ្តល់ប្រាក់ឧបត្ថម្ភ ១០០ ភាគរយ លើប្រាក់បៀវត្សសុទ្ធសាធ ដល់កងកំលាំងនគរបាលដែលឈរជើង នៅតាមសមរភូមិព្រំដែនកម្ពុជា - ថៃ ដូចមានកំណត់ក្នុងសេចក្តីសំរេចលេខ ១៣៣ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។ ឯចំនួនអង្គភាពនគរបាល និង ចំនួននគរបាលដែលត្រូវទទួលប្រាក់ឧបត្ថម្ភ គឺ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃកំណត់ ។

ជ — កងកម្លាំងនគរបាល ត្រូវបានទទួលប្រាក់ឧបត្ថម្ភពេលចេញទៅបំពេញបេសកកម្ម និង

Downloaded from http://www.khmerlaws.com

ត្រូវបានទទួលប្រាក់ឧបត្ថម្ភ ២៥៛ មួយនាក់ មួយថ្ងៃ នៅពេលអង្គភាពចាត់តាំងអោយចេញធ្វើប្រតិបត្តិការសឹក ។

ឈ - កងកម្លាំងនគរបាល ត្រូវបានទទួលប្រាក់បំណាច់តំបន់ ប្រាក់បំណាច់ប៉ះពាល់សុខភាព ។ល។ ឯមូលដ្ឋានសំរាប់គិតគូរបណ្តាប្រាក់បំណាច់ទាំងអស់នោះ គឺ ផ្អែកលើប្រាក់បៀវត្សសុទ្ធសាធ ។

ញ - កងកម្លាំងនគរបាល ត្រូវបានទទួលប្រាក់បំណាច់មុខជំនាញពី ១០ ភាគរយទៅ ២៥ ភាគរយ លើបៀវត្សសុទ្ធសាធ តាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

ដ - កងកម្លាំងនគរបាល ត្រូវបានទទួលប្រាក់បន្ថែមក្នុងថ្ងៃបុណ្យជាតិ បុណ្យអន្តរជាតិក្នុងមួយឆ្នាំមាន ៦ ថ្ងៃ ដោយផ្តល់អោយមួយនាក់ ៥០ រៀល ។

ឋ - កងកម្លាំងនគរបាល ត្រូវបានទទួលរបបឧបត្ថម្ភកូន ០១ នាក់ ៣០៛ ក្នុងមួយខែ និងមានសិទ្ធទិញអង្ករ ១០ គក្រ ក្នុងមួយនាក់ ក្នុងមួយខែ ទិញក្រណាត់ប្រចាំឆ្នាំចំនួន ០៣ ម៉ែត្រ ក្នុងមួយនាក់ តាមតម្លៃផ្គត់ផ្គង់របស់រដ្ឋ ចំពោះកូនដែលមានអាយុតិចជាង ១០ ឆ្នាំ ឬ មានអាយុលើសពី ១៥ ឆ្នាំ ដែលកំពុងសិក្សា ហើយគ្មានអាហាររូបករណ៍ ។

ចំពោះអ្នកតាមហូប ត្រូវបានអនុញ្ញាតអោយទិញអង្ករ ១០ គក្រ ជាសរុបតាមតម្លៃផ្គត់ផ្គង់របស់រដ្ឋ ។

ឌ - ចំពោះរបបឧបត្ថម្ភផ្សេងៗទៀត របស់កងកម្លាំងនគរបាល ដែលគ្មានកំណត់ក្នុងសេចក្តីសំរេចនេះ ត្រូវអនុវត្តតាមការណែនាំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

*ប្រការ ៧* : បទបញ្ញត្តិពីមុន ដែលមានខ្លឹមសារ ផ្ទុយពីសេចក្តីសំរេចនេះ ត្រូវបានចាត់ទុកជានិរាករណ៍ ។

*ប្រការ ៨* : ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ និង គណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ត្រូវអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និងត្រា

ហ៊ុន សែន

Downloaded from http://www.khmerlaws.com

តារាង ក ១

# តារាងប្រាក់មុខតំណែង
# កងកម្លាំងនគរបាល

| ល.រ | មុខតំណែង | ប្រាក់បំណាច់ |
|---|---|---|
| ១ | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ៥៧៤៛០០ |
| ២ | អនុរដ្ឋមន្ត្រី | ៥៣២៛០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៤៧០៛០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ៤៤៥៛០០ |
| ៥ | ប្រធានការិយាល័យក្រសួង | ៤២០៛០០ |
| ៦ | អនុប្រធានការិយាល័យក្រសួង | ៣៩៥៛០០ |
| ៧ | អនុប្រធានការិយាល័យ មន្ទីរនគរបាល ខេត្ត-ក្រុង កំពង់សោម | ៣៧៥៛០០ |
| ៨ | ប្រធានកងអនុសេនាធំ | ៣៣៥៛០០ |
| ៩ | អនុប្រធានកងអនុសេនាធំ | ៣១៥៛០០ |
| ១០ | ប្រធានកងអនុសេនាតូច | ២៨៥៛០០ |
| ១១ | អនុប្រធានកងអនុសេនាតូច | ២៥០៛០០ |
| ១២ | ប្រធានក្រុម | ២៤៩៛០០ |
| ១៣ | អនុប្រធានក្រុម | ២៤៤៛០០ |
| ១៤ | យុទ្ធជន | ២៣៤៛០០ |

Downloaded from http://www.khmerlaws.com

តារាងក ២ •

## តារាងប្រាក់ឋានន្តរស័ក្តិ
## របស់កងកម្លាំងនគរបាល

| លេខ | ឋានន្តរស័ក្តិ | ប្រាក់បំណាច់ |
|---|---|---|
| ១ | ឧត្តមសេនីយឯក | ២៨៧៛០០ |
| ២ | ឧត្តមសេនីយទោ | ២៧៦៛០០ |
| ៣ | ឧត្តមសេនីយត្រី | ២៥៨៛០០ |
| ៤ | វរៈសេនីយឯក | ២៤៦៛០០ |
| ៥ | វរៈសេនីយទោ | ២២៨៛០០ |
| ៦ | វរៈសេនីយត្រី | ២១៩៛០០ |
| ៧ | អនុសេនីយឯក | ១៩២៛០០ |
| ៨ | អនុសេនីយឯកបំរុង | ១៧២៛០០ |
| ៩ | អនុសេនីយទោ | ១៧២៛០០ |
| ១០ | អនុសេនីយត្រី | ១៦២៛០០ |
| ១១ | ពលបាលឯក | ១៣០៛០០ |
| ១២ | ពលបាលទោ | ១២៦៛០០ |
| ១៣ | ពលបាលត្រី | ១២៣៛០០ |
| ១៤ | ពលឯក | ១២០៛០០ |
| ១៥ | ពលទោ | ១១៧៛០០ |

Downloaded from http://www.khmerlaws.com

## បៀវត្សនគរបាលបច្ចេកទេសជំនាញ

| ថ្នាក់ | ១ | ២ | ៣ | ៤ | ៥ | ៦ | បច្ចេកទេស និងវិទ្យាសាស្ត្រ | អប់រំ | សុខាភិបាល | រដ្ឋបាលនិងផ្នែកសកម្មភាពផ្សេង ៗ ទៀត |
|---|---|---|---|---|---|---|---|---|---|---|
| | បៀវត្ស | បៀវត្ស | បៀវត្ស | បៀវត្ស | បៀវត្ស | បៀវត្ស | | | | |
| ១ I | ២៨៥ | ៣០៨ | ៣៣៨ | ៣៦៨ | ៣៩៨ | ៤៣០ | វិស្វករ | សាស្ត្រាចារ្យ | វេជ្ជបណ្ឌិត | មុខងារដែលមានសញ្ញាប័ត្រស្មើគ្នា |
| ១ II | ២៤០ | ២៥០ | ២៩០ | ៣០៨ | ៣៣៤ | ៣៦០ | បច្ចេកទេស | សាស្ត្រាចារ្យកំរិតសិក្សាទី ២ | គ្រូពេទ្យមេដីសាំង | មុខងារដែលមានសញ្ញាប័ត្រស្មើគ្នា |
| ១ III | ១៩៥ | ២១០ | ២៣០ | ២៥០ | ២៧០ | ២៩៥ | អ្នកបច្ចេកទេស | គ្រូកំរិតសិក្សាទី ១ ១.៣.១ | គិលានុបដ្ឋានឧត្តម | មុខងារដែលមានសញ្ញាប័ត្រស្មើគ្នា |

*កំណត់សំគាល់* : ១ - ប្រភេទកម្មាភិបាល បុគ្គលិក ត្រូវផ្អែកទៅលើកំរិតបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែករដ្ឋបាល និងសកម្មភាពផ្សេង ៗ ទៀតក្រៅពីបច្ចេកទេស វិទ្យាសាស្ត្រ អប់រំ សុខាភិបាល ត្រូវមានកំរិតអប់រំបណ្តុះបណ្តាលស្មើគ្នា ស្នើដោយក្រសួង មន្ទីរ សាមី ហើយអនុវត្តបានលុះត្រាតែមានការព្រមព្រៀងជាមុនពីក្រសួងផែនការ ។

២ - ប្រភេទនិមួយ ៗ ចែកចេញជា ៦ ថ្នាក់ ។ ថ្នាក់ទី ១ " ដោយពុំគិតបញ្ចូលរយៈពេលកម្មសិក្សា ៦ ខែ ១២ ខែ ១៨ ខែ " និង [illegible]

Downloaded from http://www.khmerlaws.com

តារាង "គ"

បៀវត្សកម្មករនគរបាល

| ការ ក្រុមមុខរបរ | ១ បៀវត្ស | ២ បៀវត្ស | ៣ បៀវត្ស | ៤ បៀវត្ស | ៥ បៀវត្ស | ៦ បៀវត្ស | បណ្ដាមុខរបរបស់កម្មករ |
|---|---|---|---|---|---|---|---|
| គ I | ២៣៤ | ២៥៤ | ២៨៩ | ៣២៤ | ៣២៩ | ៣៥៥ | - ជាងម៉ាស៊ីន ជាងអគ្គិសនី ជាងសំណង់ ជាងស្ពាន-ថ្នល់<br>- អ្នកបើកត្រាក់ទ័រ អ្នកបើកបររថយន្តដឹកជញ្ជូនគុកធ្ងន់បំផុត<br>- ឧស្សាហកម្ម ជាងម៉ាស៊ីនពោសក្បាលណ្ឌ ...... ។ល។ |
| គ II | ២១៣ | ២៣៤ | ២៦១ | ២៨៨ | ៣១៥ | ៣៤២ | - កម្មករជៀងផ៉ែរ កម្មករតម្បាញ កម្មករធ្វើកៅស៊ូកង់រថយន្ត ខោចក្រ<br>- សំភារៈសំណង់ កម្មករស្រែអំបិល<br>- អ្នកបើកបររថយន្តដឹកជញ្ជូនធុនធ្ងន់ ស្រាល និង ធុនមធ្យម<br>- កម្មករកំពង់ផែ ...... ។ល។ |
| គ III | ១៩២ | ២១០ | ២៣៤ | ២៥៥ | ២៨៣ | ៣០៥ | - កម្មកររោងចក្រទឹកក្រូច ទឹកកក ឧស្សាហកម្មស្បៀង<br>- អ្នកលក់ដូរតាមសណ្ឋាគារ ផ្ទះភ្ញៀវ ជាងកាត់ខោអាវ |
| គ IV | ១៧០ | ១៨៣ | ១៧០ | ១៨៣ | ២០៤ | ២២៤ | - ពលករសាធារណៈនៅតាមមន្ទីរក្រសួង រោងចក្រ សហគ្រាស<br>- អ្នកបោសសំអាត អ្នកយាមទ្វារ .... ។ល។ |

***កំណត់សំគាល់***

១- ក្រុមមុខរបរត្រូវផ្អែកទៅលើចរិកលក្ខណៈបច្ចេកទេសនៃផលិតកម្ម និង លក្ខខណ្ឌការងារខុស ៗ គ្នា

២- ការវែងថែកការត្រូវផ្អែកលើលំដាប់បច្ចេកទេសនៃមុខរបរនិមួយៗ ។ បច្ចុប្បន្នត្រូវផ្អែកលើកំរិតចិន្ន និងទៅលើអតីតភាពនៃវិជ្ជាជីវៈផង ។

ការទី ១ និងការទី ២ ត្រូវមានអតីតភាព ៣ ឆ្នាំ ។ ចាប់ពីការទី ៣ ឡើងទៅត្រូវមានអតីតភាព ៤ ឆ្នាំ ។

មុននឹងរៀនចំក្នុងការនៃក្រុម គ ១ គ ២ កម្មករត្រូវឆ្លងកាត់បណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅតាមសាលា ឬ នៅកន្លែងធ្វើការផ្ទាល់ ។

...ប្រាក់... តំលៃរបៀបចំដំបងចលកុងតារាង គ ៤ ការ ១ | ១៧០,០០ ។

តារាង ឃ

## តារាងប្រាក់អតីតភាពរបស់កងកម្លាំង នគរបាល

| រយៈពេលបំរើក្នុងកងកម្លាំង នគរបាល | សមាមាត្រត្រូវបានទទួលប្រៀបធៀប លើបៀវត្សសុទ្ធសាធ |
|---|---|
| ពីឆ្នាំទី ៤ ដល់ឆ្នាំទី ៥ | ៥ ភាគរយ |
| ពីឆ្នាំទី ៦ ដល់ឆ្នាំទី ១០ | ១០ ភាគរយ |
| ពីឆ្នាំទី ១១ ដល់ឆ្នាំទី ១៥ | ១៥ ភាគរយ |
| ពីឆ្នាំទី ១៦ ដល់ឆ្នាំទី ២០ | ២០ ភាគរយ |
| ពីឆ្នាំទី ២១ ដល់ឆ្នាំទី ២៥ | ២៥ ភាគរយ |
| ពីឆ្នាំទី ២៦ ដល់ឆ្នាំទី ៣០ | ៣០ ភាគរយ |
| ពីឆ្នាំទី ៣១ តទៅ | ៤០ ភាគរយ |

Downloaded from http://www.khmerlaws.com

សហគ្រាសសម្ព័ន្ធរោងពុម្ព

បោះពុម្ពនៅរោងពុម្ពពាណិជ្ជកម្ម

លើកទី ១ ចំនួន ៩.០០០ ច្បាប់

Downloaded from http://www.khmerlaws.com